ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

លេខ......៨៧៧៧...... អ.ន.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការត្រៀមអន្តរាគមន៍កំចាត់ដង្កូវហ្វូងលើដំណាំស្រូវ

ដង្កូវហ្វូងត្រូវបានចាត់ទុកជាសត្វល្អិតចង្រៃចម្បងមួយប្រភេទនៅអាស៊ី។ នៅប្រទេសកម្ពុជាយើង ជារៀងរាល់ឆ្នាំមានដំណាំជា ច្រើនមុខ ដូចជា ស្លែ សណ្តែក ពោត។ល។ តែងរងនូវការបំផ្លាញដោយដង្កូវហ្វូងនេះ។ ដោយឡែក ដំណាំស្រូវក៏តែងទទួលរងនូវការបំផ្លាញច្រើននាដើមរដូវវស្សានៅឆ្នាំណាដែលជួបប្រទះគ្រោះរាំងស្ងួតខ្លាំង ព្រោះនៅពេលភ្លៀងដើមរដូវ រុក្ខជាតិទាំងឡាយចាប់ផ្តើមដុះលូតលាស់ល្អបង្កើតបានជាជម្រក និងចំណីអាហារសមស្រប ធ្វើឱ្យវាមានលទ្ធភាពបង្កើនកូនចៅបានច្រើន ហើយបន្ទាប់មក មានការរាំងស្ងួតអូសបន្លាយធ្វើឱ្យមានការបាត់បង់ដល់ពពួកសត្វមានប្រយោជន៍ផងនោះ ដង្កូវហ្វូងក៏មានលទ្ធភាពបង្កើនប្រជាករ និងរាលដាលបំផ្លាញដំណាំស្រូវពីស្រែមួយទៅស្រែមួយទៀតទាំងហ្វូងៗ ចំពោះស្រែគ្មានទឹក វាកាត់ស៊ីដល់គល់តែម្តង ចំណែកឯស្រែមានទឹកវិញ វាកាត់ស៊ីផ្នែកខាងលើទឹកទាំងអស់។

ឆ្នាំនេះ ដោយយោងតាមលក្ខខណ្ឌធម្មជាតិនៅប្រទេសយើងប្រែប្រួល រាំងស្ងួត ក្តៅខ្លាំង បានអូសបន្លាយយូរ បង្កឱ្យមានភាពងាយស្រួលដល់ការកកើត និងរាលដាលនៃពួកដង្កូវហ្វូងនេះយ៉ាងឆាប់រហ័សក្រោយពីមានភ្លៀងធ្លាក់ដើមដែមក។

នៅដើមខែមិថុនានេះ ដង្កូវហ្វូងបានផ្ទុះនៅក្នុងខេត្តមួយចំនួនដូចជា កំពង់ចាម ព្រៃវែង ត្បូងឃ្មុំ ព្រះវិហារ និងឧត្តរមានជ័យ ស្ថិតក្នុងស្ថានភាពនេះ ដើម្បីទប់ស្កាត់ការរីករាលនិងបំផ្លាញពីដង្កូវហ្វូង អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមណែនាំពីវិធីសាស្ត្រកំចាត់ដង្កូវហ្វូងដូចខាងក្រោមដល់បងប្អូនកសិករគ្រប់រាជធានី ខេត្តៈ

+ វិធីសាស្ត្រទី១៖ ប្រើអន្ទាក់ជូរអែមនៅពេលយប់ដើម្បីកំចាត់មេអំបៅដង្កូវហ្វូង:

ក. <u>វិធីធ្វើអន្ទាក់ជូរអែមគឺ:</u> ដាក់ទឹក១ភាគ ស្រាស១ភាគ ស្កររង្វ៤ភាគ ទឹកខ្មេះ៤ភាគ ហើយលាយបញ្ចូលគ្នាឱ្យសព្វ។ បន្ទាប់មក លាយថ្នាំ Fipronil ២ម.ល ក្នុងសូលុយស្យុង ១លីត្រ។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (០២៣) ៨៨៣ ៤២៧. ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh, Cambodia, Phone : (023) 883 427, Fax : (023) 883 427

ខ. <u>របៀបប្រើ:</u> យកសូលុយស្យុងខាងលើដាក់ក្នុងចានដ៏រស្ដើង ឬជ្រលក់នឹងសំឡីដក់ទឹក បន្ទាប់មកយកចងព្យួរ តាមចំការនៅពេលយប់ ហើយដាក់ឱ្យខ្ពស់ផុតពីដី ការពារការប៉ះពាល់ដល់សត្វចិញ្ចឹមផ្សេងៗ។ ក្លិននៃអន្ទាក់ជូរអែមនេះ វាទាក់ទាញមេអំបៅមកជញ្ជក់ បន្ទាប់មកវាងាប់។

+ វិធីសាស្ត្រទី២៖ កំចាត់ដង្កូវហ្វូង

- ចំពោះចំការ ឬស្រែដែលគ្មានទឹក
  - ជីកចង្អូរនៅតាមព្រំចំការ ឬស្រែដែលជាប់ជាមួយព្រៃ ឬចំការចេក ឬមានស្មៅចង្រៃដុះច្រើននៅតាមព្រំ (ចង្អូរមានមុខលើទំហំ៣០ស.ម ជម្រៅ២០ស.ម រួចរាយផេះពីលើ ឬនៅពេលដង្កូវចូលច្រើនអាចបាញ់ថ្នាំតាមចង្អូរនេះក៏បាន)
  - ប្រើមែកឈើស្រស់ ឬវត្ថុជាតុដទៃដែលអាចធ្វើជាម្លប់ យកទៅរាយក្នុងចំការ ឬស្រែ ដោយដាក់គំលាតពីមួយទៅមួយប្រហែលពី៤ ទៅ ៥ម៉ែត្រ (ពេលវេលាដែលត្រូវដាក់ចាប់ពីម៉ោង ៧:៣០ នាទីព្រឹក រហូតដល់ម៉ោង ៣ល្ងាច ក្នុងករណីមេឃស្រលះ មានថ្ងៃក្តៅខ្លាំង) បន្ទាប់មករាល់ ២ ទៅ៣ម៉ោងម្តង យើងអាចប្រមូលដង្កូវដើម្បីកំទេចចោល។
- ចំពោះស្រែដែលមានទឹក ឬជិតប្រភពទឹកត្រូវបញ្ចូលទឹកទៅក្នុងសំណាប ឬសន្ទូងអោយលិចចុងស្រូវ រួចប្រើស្បៃមុងអូសប្រមូលដង្កូវយកទៅកំទេចចោល។

+ វិធីសាស្ត្រទី៣៖ កំទេចប្រភពដង្កូវហ្វូងនៅជុំវិញចំការ ឬស្រែ

- សំអាតស្មៅចង្រៃ ប្រមូលកំទេចកំទីដែលជាជម្រក និងជាប្រភពដង្កូវហ្វូងលាក់ខ្លួនយកទៅដុតកំទេចចោល
- ជម្រើសចុងក្រោយអាចបាញ់ថ្នាំកសិកម្មកំចាត់ដង្កូវហ្វូងដែលលាក់ខ្លួននៅក្នុងស្មៅចង្រៃ គុម្ពចេក ឬដំណាំឈើហូបផ្លែដទៃទៀតដែលនៅជុំវិញស្រែចំការ (វិធីសាស្ត្រនេះគឺប្រើថ្នាំកសិកម្មកំចាត់ប្រភពដង្កូវក្នុងទ្រង់ទ្រាយតូច តែមានប្រសិទ្ធភាពខ្ពស់)។ ថ្នាំកសិកម្មមួយចំនួនដែលត្រូវប្រើក្នុងករណីចាំបាច់ដូចជា៖
  - Thuricide ឬ Dipel ក្នុងកំរិតប្រើ ១ គីឡូក្រាម លើផ្ទៃដី ១ ហិកតា
  - Buprofezin ត្រូវប្រើក្នុងកំរិត ០.៧-១ គក្រ/ហត និង Fenobucarb ត្រូវប្រើក្នុងកំរិត ១.៥-២ លីត្រ/ហត
  - ថ្នាំសម្លាប់សត្វល្អិតក្នុងក្រុម Pyrethroid ដូចជា Cypermethrin ឬ Deltamethrin ក្នុងកម្រិតប្រើ ១លីត្រ លើផ្ទៃដី ១ ហិកតា
  - ថ្នាំសម្លាប់សត្វល្អិតក្នុងក្រុម Carbomate ដូចជា Carbaryl ក្នុងកំរិតប្រើដូចខាងលើ
  - ថ្នាំសម្លាប់សត្វល្អិតដូចរៀបរាប់ខាងលើពុំសូវមានឥទ្ធិពលអាក្រក់ដល់បរិស្ថានប៉ុន្មានទេ។

អគ្គនាយកដ្ឋានកសិកម្ម សូមសំណូមពរដល់បងប្អូនកសិករ អាជ្ញាធរដែនដី ពិសេសមន្ទីរកសិកម្ម រាជធានី ខេត្ត មេត្តាសហការចាត់វិធានការណ៍ជាបន្ទាន់តាមការណែនាំខាងលើ តាមទីកន្លែងដែលកើតមានជង្គូវហ្វូងនេះ។

ក្នុងករណីធ្ងន់ធ្ងរសូមមេត្តារាយការណ៍មក អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាបន្ទាន់ ឬតាមរយៈលេខទូរស័ព្ទ ០១២ ៣៣៦ ៩៣៤ និង/ឬ ០១២ ៣៣៥ ៩៥៦។

សូមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**ស៊ូ-ខនឬទ្ធីគុណា**

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម ទី សុគន្ធ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម អ៊ឹង ហុកលីម អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- នាយកដ្ឋានកិច្ចការរដ្ឋបាល

  " <u>ដើម្បីគោរពជូនជ្រាប</u> "
- គ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត

  " <u>ដើម្បីមុខការ</u> "

-ឯកសារ/កាលប្បវត្តិ